Thu Aug 03 2017 14:51:19 GMT+0700 (SE Asia Standard Time) Login - Register | FOLLOW US ON

ភ្នំពេញ ប៉ុស្តិ៍



# ក្រុមហ៊ុន Geopacific Resources គ្រោងទិញភាគហ៊ុនរបស់ក្រុមហ៊ុន GRD

Fri, 4 January 2013 ម៉ៃ គុណមករា and Sarah Thust




ក្រុមកុមារ កំពុងដើរលេងនៅលើស្ពានមួយនៅពីលើអណ្ដូងរ៉ែដ៏ជ្រៅ ដែលមានទីតាំងស្ថិតនៅខេត្តមណ្ឌលគិរី Don Weinland

**ភ្នំពេញៈ**ក្រុមហ៊ុនរុករករ៉ែរបស់អូស្ត្រាលីGeopacific Resources ដែលបានផ្តោតជាសំខាន់លើគម្រោងរុករករ៉ែមាស និងទង់ដែង នៅកោះហ្វីជីចង់ទិញភាគហ៊ុនរបស់ក្រុមហ៊ុន Worldwide Mining Projects Limited (WWM ) ដែលជាក្រុមហ៊ុនរុករករ៉ែនៅអាស៊ីអាគ្នេយ៍។

ក្រុមហ៊ុន Worldwide Mining Projects Limitedបានចុះកិច្ចព្រមព្រៀងលើការលក់ភាគហ៊ុននេះជាមួយក្រុមហ៊ុនGolden Resources Development ដែលជាក្រុមហ៊ុននៅកម្ពុជាគ្រប់គ្រងដោយកូរ៉េខាងត្បូង។ នេះបើយោងតាមសេចក្ដីប្រកាសព័ត៌មានកាលពីម្សិលមិញ។

កិច្ចព្រមព្រៀងលក់នេះ ជាជម្រើសមួយដើម្បីទទួលបានភាគហ៊ុន៨៥ភាគរយនៅក្នុងគម្រោងរុករករ៉ែទង់ដែង គូសា នៅភាគខាងជើងប្រទេសកម្ពុជា ចំណែក១៥ភាគរយទៀតនឹងគ្រប់គ្រងដោយក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប។

នៅក្នុងសេចក្តីប្រកាសព័ត៌មាននោះ បានលើកឡើងថាៈ «ការទិញភាគហ៊ុនដ៏ជោគជ័យនេះ នឹងធ្វើឲ្យក្រុមហ៊ុនGeopacific Resourcesទទួលបានភាគហ៊ុន ៨៥ភាគរយ នៅក្នុងគម្រោងរុករករ៉ែKou Sa Copper នៅកម្ពុជា»។

ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបរបស់លោកគិត ម៉េង ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយនៃដៃគូកម្ពុជារបស់ក្រុមហ៊ុនWWMនឹងចែករំលែកភាគហ៊ុន១៥ភាគរយនៅក្នុងគម្រោងនេះ។ ថ្វីបើយ៉ាងនេះក្ដី នៅពេលភ្នំពេញ ប៉ុស្តិ៍ សាកសួរលោកអំពីបញ្ហានេះ កាលពីថ្ងៃព្រហស្បតិ៍ លោកបានឆ្លើយថា លោកមិនដឹងអំពីព័ត៌មាននេះឡើយ។

សេចក្តីប្រកាសព័ត៌មានដដែលនេះ បានបន្ថែមទៀតថាៈ «ក្រុមហ៊ុន Geopacificរីករាយនឹងចូលរួមជាមួយដៃគូដ៏ល្បីល្បាញ និងគួរជាទីគោរពនៅក្នុងក្រុមហ៊ុនរ៉ូយ៉ាល់ គ្រុប ដែលជាក្រុមហ៊ុនធំជាងគេនៅកម្ពុជា»។

លោក គង់ មករា ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលប្រចាំខេត្តព្រះវិហារ បានថ្លែងថា ក្រុមហ៊ុន Golden Resource development បានទទួលអាជ្ញាប័ណ្ណពីរដ្ឋាភិបាលកាលពីឆ្នាំ២០០៩ ដោយទទួលបានដីសម្បទានជាង១៧០ហិកតា នៅស្រុកជឹបដើម្បីសិក្សាអំពីលទ្ធភាពរករ៉ែមាស និងទង់ដែង។ លោកបានឲ្យដឹងថា អាជ្ញាប័ណ្ណនេះ នឹងមានរយៈពេល៦ឆ្នាំ។

## ព័ត៌មានពាក់ព័ន្ធ

- ក្រុមហ៊ុនរ៉ែអូស្ត្រាលីពង្រីកតំបន់រករ៉ែទង់ដែងនៅកម្ពុជា
- ក្រុមហ៊ុនរ៉ែអូស្ត្រាលីបញ្ជាក់ថាខ្លួនជោគជ័យនៅកម្ពុជា
- ក្រុមហ៊ុន Geopacific រកឃើញរ៉ែមាស ប្រាក់បន្ថែម
- ក្រុមហ៊ុនរ៉ែអូស្ត្រាលីបង្ហាញលទ្ធផលវិជ្ជមាននៅកម្ពុជា
- កម្ពុជាអះអាងពីការរកឃើញរ៉ែមាសរហូតជិត ៤០តោន
- ក្រុមហ៊ុន អូស្ត្រាលី សម្រេចកិច្ចព្រមព្រៀងអណ្ដូងរ៉ែ
- Rio Tinto និងម៉ុងហ្គោលីចុះកិច្ចព្រមព្រៀងគម្រោងរ៉ែ
- មន្ត្រីកម្ពុជាទៅអង្កេតមើលឧស្សាហកម្មរ៉ែអូស្ត្រាលី

## វីដេអូថ្មីបំផុត



តោះ! អ្នកចូលចិត្តទុរេន មកសាកបង្អែមទឹកកកឈូសផ្លែឈើផ្អែមឆ្ងាញ់



ករណីចាប់ក្មេងរះយកគ្រឿងក្នុង អាចជាព័ត៌មានបំពុលសង្គម

ទទួលព័ត៌មានរហ័ស

លោកបានលើកឡើងថា៖ «ពួកគេ កំពុងសិក្សាអំពីលទ្ធភាពនេះ។ ខ្ញុំតែងតែត្រួតពិនិត្យជាមួយពួកគេអំពីការរីកចម្រើននេះ។ ថ្វីបើយ៉ាងនេះក្តី ខ្ញុំមិនដឹងអំពីលទ្ធផលនេះឡើយ ដោយសារពួកគេតែងតែរក្សាការសម្ងាត់ និងរាយការណ៍មកតែក្រសួងប៉ុណ្ណោះ មិនមែនមន្ទីររបស់ខ្ញុំឡើយ»។

សេចក្តីប្រកាសព័ត៌មានបានបង្ហាញថា ក្រុមហ៊ុន Geopacific Resources បានរកឃើញរ៉ែមាស ទង់ដែង ស័ង្កសី និងប្រាក់ដ៏ច្រើន នៅក្នុងអណ្តូងដែលបានខួងចំនួន២០ នៅគម្រោង គូសា ក្នុងខេត្តព្រះវិហារ។ ការធ្វើតេស្តបន្ថែមនឹងធ្វើឡើងក្នុងរយៈពេល១២ខែក្រោយ មុនពេលមានការសម្រេចចិត្តចុងក្រោយរបស់ក្រុមហ៊ុនGeopacific Resources។

យោងតាមកិច្ចព្រមព្រៀងនេះ សេចក្តីប្រកាសព័ត៌មាននោះ បានបង្ហាញថាក្រុមហ៊ុនWWMនឹងបង់ប្រាក់ឲ្យក្រុមហ៊ុន GRD សរុបចំនួន៧០ម៉ឺនដុល្លារអាមេរិកមុនថ្ងៃទី៣១ខែមករាឆ្នាំ២០១៣នេះ។

ជម្រើសទិញភាគហ៊ុនក្នុងគម្រោងរុករករ៉ែទង់ដែង គូសា នឹងចំណាយពេល ១២ខែដើម្បីវាយតម្លៃសក្តានុពលសេដ្ឋកិច្ចរបស់គម្រោង មុនពេលសម្រេចចិត្តធ្វើ ឬពន្យារពេលជម្រើសនេះ១២ខែបន្ថែមទៀត(ក្នុងតម្លៃចំនួន៧០ម៉ឺនដុល្លារ)។

សេចក្តីប្រកាសព័ត៌មាននោះ បានបង្ហាញថា ទាក់ទងនឹងការអនុវត្តជម្រើសនេះ ក្រុមហ៊ុន Geopacificនឹងចាំបាច់បង់ប្រាក់ចំនួន១៤លានដុល្លារអាមេរិកទៅឲ្យក្រុមហ៊ុន GRD ដើម្បីទិញគម្រោងនេះ ដែលក្រុមហ៊ុនWWMនឹងមានភាគហ៊ុន៨៥ភាគរយ ហើយរ៉ូយ៉ាល់គ្រុប នឹងមាន១៥ភាគរយ រហូតដល់ការសម្រេចចិត្តរុករករ៉ែ ត្រូវបានធ្វើឡើង៕ CS

---

0 Comments

Please, login or register to post a comment

The Phnom Penh Post
ភ្នំពេញ ប៉ុស្តិ៍

Post Media Co Ltd
888 Building H, 8th Floor, Phnom Penh Center
Corner Sothearos & Sihanoulk Blvd
Sangkat Tonle Bassac
12301 Phnom Penh
Cambodia

Tel: +855(0) 23 214 3 11-17
Fax: +855(0) 23 214 318

Company
Staff list

មាតិកា
ប៉ុស្តិ៍ អចលនទ្រព្យ
របាយការណ៍
ពិសេស
LIFT
ព័ត៌មានរូបភាព
កម្រងវីឌីអូ

បណ្ណសារ
កម្ពុជាចុងសប្តាហ៍
នរណាជានរណា
ឃ្លាំមើលការបោះឆ្នោត
ឃ្លាំមើលរឿងខ្មែរ
ក្រហម
CEO Talk

Facebook Twitter Google +

SEVENDAYS

LIFT THE ESSENTIAL MAGAZINE FOR CAMBODIAN YOUTH.

Copyright © 2013 The Phnom Penh Post. All Rights Reserved. Web design by IConsulting